01647950

F56/2/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jul-2020, 13:36
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

# សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងការមិនអនុវត្តន៍របស់ ខៀវ សំផន តាមមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda HOLLIS

**ជនជាប់ចោទ**
ខៀវ សំផន

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Megan HIRST

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួលសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការមិនអនុវត្តន៍របស់ ខៀវ សំផន តាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ("សំណើ") ដែលបានដាក់នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០[1]។

## ក. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ខៀវ សំផន ("មេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាបារាំង[2]។ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២០ សំណៅបកប្រែជាភាសាអង់គ្លេសត្រូវបានជូនដំណឹង។

2. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") បានដាក់សំណើនេះ។

3. នៅថ្ងៃទី ០១ និង ០៤ ខែ មិថុនា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី បានដាក់សារណាតបរៀងៗខ្លួន[3]។

4. នៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២០ សហមេធាវីនាំមុខ បានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងសារណាតបរបស់មេធាវីការពារក្តី[4]។

---

[1] សំណើពាក់ព័ន្ធទៅនឹងការមិនអនុវត្តន៍របស់ ខៀវ សំផន ស្របតាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ឯកសារលេខ **F56** ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ("សំណើសុំ")។

[2] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (002/02) ឯកសារលេខ **F54** ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ("សារណាបណ្តឹងសាទុក្ខ")។

[3] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការមិនអនុវត្តន៍របស់ ខៀវ សំផន តាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ឯកសារលេខ **F56/1** ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២០ ("សារណាតបរបស់សហព្រះរាជអាជ្ញា")។ សារណាតបរបស់មេធាវីការពារក្តីទៅនឹងសំណើសុំរបស់សហមេធាវីនាំមុខ ពាក់ព័ន្ធទៅនឹងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ ឯកសារលេខ **F56/2** ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២០ ("សារណាតបរបស់មេធាវីការពារក្តី")។

5. ការកែតម្រូវរបស់មេធាវីការពារក្តីលើសារណាបណ្តឹងសាទុក្ខ ត្រូវបានដាក់នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០[5]។

6. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២០ សំណៅបកប្រែជាភាសាខ្មែរលើសារណាបណ្តឹងសាទុក្ខ ត្រូវបានជូនដំណឹង។

## ខ. សារណា

***<u>សំណើ</u>***

7. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា តារាងសំអាងផ្លូវច្បាប់ដែលបានដាក់ជាមួយនឹងបណ្តឹងសាទុក្ខ (“TOA”) ពុំបានអនុវត្តតាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. (“មាត្រា ៦”) ដោយមូលហេតុថា (i) សំអាងផ្លូវច្បាប់មួយចំនួនពុំមាននៅក្នុងតារាង TOA (ii) មួយចំនួនមាននៅក្នុងសំណុំរឿង ប៉ុន្តែពុំបានកំណត់អត្តសញ្ញាណត្រឹមត្រូវ និង (iii) ខ្លះទៀតពុំមាននៅក្នុងសំណុំរឿង និងភ្ជាប់មកជាមួយឡើយ[6]។ ដូច្នេះ សហមេធាវីស្នើសុំអង្គជំនុំជម្រះ (i) ណែនាំមេធាវីការពារក្តីឱ្យដាក់តារាងពេញលេញឡើងវិញរួមទាំងឧបសម្ពន្ធដោយអនុលោមតាមវិធាន ៦ អោយបានឆាប់រហ័សបំផុត និង (ii) អនុញ្ញាតឱ្យសហមេធាវីដាក់តារាងរបស់ខ្លួន និងឯកសារចម្លងនៃសំអាងផ្លូវច្បាប់ក្នុងរយៈពេល ២៨ ថ្ងៃគិតចាប់ពីពេលដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខ(“សារណាតប”) ជាការសងទូទាត់លើការខាតបង់ពេលវេលា និងទទួលអត្ថប្រយោជន៍ដូចគ្នាទៅនឹងមេធាវីការពារក្តី[7]។

***<u>សារណាតបរបស់សហព្រះរាជអាជ្ញា</u>***

---

[4] ការឆ្លើយតបទៅនឹង ខៀវ សំផន ពាក់ព័ន្ធទៅនឹងការមិនអនុវត្តន៍តាម មាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ (“ការឆ្លើយតប”) ឯកសារលេខ **F56/2/1** ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២០។

[5] សំណើសុំកែតម្រូវលើឯកសារលេខ **F54** ឯកសារលេខ **F54/Corr-1** ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០ និងជូនដំណឹង នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២០។

[6] សំណើសុំ កថាខណ្ឌ ៥ ដល់ ៧។

[7] សំណើសុំ កថាខណ្ឌ ២ ៧ ៩។

8. សហព្រះរាជអាជ្ញាគាំទ្រសំណើសុំ[8]។

## *<u>សារណាតបរបស់មេធាវីការពារក្តី</u>*

9. មេធាវីការពារក្តីជំទាស់ទៅនឹងសំណើសុំនេះ និងបានស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធសំណើនេះ[9]។ ខណៈពេលទទួលស្គាល់ថា តារាងសំអាងផ្លូវច្បាប់ចាំបាច់ត្រូវកែតម្រូវ មេធាវីការពារក្តីបានលើកឡើងថា ខ្លួនមានគម្រោងធ្វើការកែតម្រូវ“ឱ្យបានឆាប់រហ័សបំផុត” បន្ទាប់ពីការដាក់ការតម្រូវលើបណ្តឹងសាទុក្ខរួចនោះ និងបានបន្ថែមថា បច្ចុប្បន្ន ខ្លួនកំពុងដំណើរការកែតម្រូវលើសារណាបណ្តឹងសាទុក្ខ[10]។ មេធាវីការពារក្តីបានអះអាងថា ការកែតម្រូវនេះនឹងធ្វើឱ្យសំណើសុំរបស់មេធាវីការពារក្តីទៅជាអសារបង់[11]។ ទាក់ទងទៅនឹងផ្នែកនៃសំណើសុំឱ្យដាក់តារាងសំអាងផ្លូវច្បាប់ឡើងវិញ“ជាមួយនឹងឧបសម្ពន្ធទាំងអស់ដែលពុំមាននៅក្នុងសំណុំរឿង ឬកម្រងឯកសារច្បាប់របស់ អ.វ.ត.ក.” មេធាវីការពារក្តីឆ្លើយតបថា ស្របតាមអនុស្សរណៈរបស់អង្គជំនុំជម្រះដែលវិសោធនកម្មលើលក្ខខណ្ឌតម្រូវក្នុងការដាក់ឯកសារចម្លងនៃសំអាងផ្លូវច្បាប់ ភាគីនៃសំណុំរឿង ០០២ លែងតម្រូវឱ្យភ្ជាប់ឯកសារដែលបានយោងនោះតទៅទៀត ដោយសារមានជាសាធារណៈរួចហើយ[12]។ មេធាវីការពារក្តីអះអាងថា សំណើក្នុងផ្នែកនេះពុំមានមូលដ្ឋានត្រឹមត្រូវ[13]។ មេធាវីបានលើកឡើងបន្ថែមទៀតថា សំណើទីពីរពុំមានលក្ខណៈសមហេតុផល និងបានអះអាងថា ខ្លួនពុំទទួលបានអត្ថប្រយោជន៍ពីបញ្ហានេះទេ និងថា ពុំមានការខាតបង់ពេលវេលាដែលត្រូវទូទាត់សងសម្រាប់ភាគីដែលឆ្លើយតបដែរ[14]។ ចុងក្រោយ មេធាវីការពារក្តីបានបញ្ជាក់ថា វាពិបាកក្នុងការយល់បានថា តើលទ្ធភាពរបស់សហមេធាវីការពារក្តីក្នុងការឆ្លើយតបទាន់ពេលវេលា អាចត្រូវរងការប៉ះដូចម្តេច ពីព្រោះ

[8] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២។

[9] សារណាតរបស់មេធាវីការពារក្តី កថាខណ្ឌ ៣ ១០ ១៧ ដល់ ១៩។

[10] សារណាតរបស់មេធាវីការពារក្តី កថាខណ្ឌ ៦ ៩។

[11] សារណាតរបស់មេធាវីការពារក្តី កថាខណ្ឌ ៩។

[12] សារណាតរបស់មេធាវីការពារក្តី កថាខណ្ឌ ៧ ដល់ ៨ យោងទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា “វិសោធនកម្មលើលក្ខខណ្ឌតម្រូវក្នុងការដាក់ឯកសារចម្លងនៃមូលដ្ឋានសំអាងផ្លូវច្បាប់” ឯកសារលេខ **E116/1/3** ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ (“អនុស្សរណៈឆ្នាំ ២០១១”)។

[13] សារណាតរបស់មេធាវីការពារក្តី កថាខណ្ឌ ៧ ១០ ដល់ ១១ ១៩។

[14] សារណាតរបស់មេធាវីការពារក្តី កថាខណ្ឌ ១៣ ដល់ ១៤ ១៧ ដល់ ១៨។

កាលបរិច្ឆេទដាក់ឯកសារពុំទាន់ចាប់ផ្តើមនៅឡើយ និងថា សហមេធាវីមានពេលវេលាគ្រប់គ្រាន់ក្នុងការដាក់សារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខ[15]។

***<u>ការឆ្លើយតបរបស់សហមេធាវីនាំមុខ</u>***

10. សហមេធាវីនាំមុខបានស្នើសុំអង្គជំនុំជម្រះឱ្យកំណត់កាលបរិច្ឆេទសម្រាប់ដាក់ឯកសារនៃសំណៅកែតម្រូវសារណាបណ្តឹងសាទុក្ខ និងតារាងសំអាងផ្លូវច្បាប់"ឱ្យបានឆាប់បំផុត" និងបានអះអាងថា ភាគីពុំគប្បីតម្រូវឱ្យឆ្លើយតបទៅនឹងឯកសារដែលមានលក្ខណៈខ្វះចន្លោះ[16]។ សហមេធាវីនាំមុខបានស្នើសុំបន្ថែមទៀតឱ្យអង្គជំនុំជម្រះបញ្ជាក់ថា ការកែតម្រូវលើខ្លឹមសារចំពោះសារណាបណ្តឹងសាទុក្ខពុំត្រូវអនុញ្ញាតឡើយ[17]។ បើទោះបីជាសហមេធាវីនាំមុខបានយល់ស្របថា អនុស្សរណៈឆ្នាំ ២០១១ លើកលែងឱ្យភាគីពុំចាំបាច់ដាក់សំអាងផ្លូវច្បាប់"ដែលអង្គជំនុំជម្រះ និងភាគីទាំងអស់អាចរកបានដោយងាយស្រួល"ក៏ដោយ ក៏សហមេធាវីបានអះអាងថា ការភ្ជាប់ឯកសារចម្លងសំអាងផ្លូវច្បាប់ដែលពុំងាយស្រួលក្នុងការស្វែងរកនោះ នៅតែជាលក្ខខណ្ឌតម្រូវ[18]។ ទាក់ទងទៅនឹងរយៈពេល ២៨ ថ្ងៃដែលបានស្នើសុំ សហមេធាវីនាំមុខបានបញ្ជាក់លម្អិតថា នៅពេលកំណត់កាលបរិច្ឆេទដាក់សារណាតបរបស់ខ្លួន អង្គជំនុំជម្រះបានពិចារណារួចរាល់លើពេលវេលាចាំបាច់ សម្រាប់ការបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខ។ ទោះជាយ៉ាងណាក្តី ពុំអាចប្រមើលដឹងថា ការកែតម្រូវលើសំអាងផ្លូវច្បាប់ (និងលើសារណាបណ្តឹងសាទុក្ខ) អាចបញ្ចប់ក្នុងរយៈពេលបីខែបន្ទាប់ពីកាលបរិច្ឆេទដាក់សារណាឡើយ[19]។ ចំពោះសហមេធាវីនាំមុខ រយៈពេលបីខែនេះ គឺជាការចំណេញផលប្រយោជន៍ដល់មេធាវីការពារក្តីដែលនេះជាការពុំយុត្តិធម៌ដល់ភាគីឆ្លើយតប[20]។

**គ. ច្បាប់ជាធរមាន**

---

[15] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ១៥ ដល់ ១៦។

[16] ការឆ្លើយតប កថាខណ្ឌ ៣ ដល់ ៤ ១២។

[17] ការឆ្លើយតប កថាខណ្ឌ ៤ ដល់ ៥ ១២។

[18] ការឆ្លើយតប កថាខណ្ឌ ៦ ដល់ ៨។

[19] ការឆ្លើយតប កថាខណ្ឌ ៩ ដល់ ១០។

[20] ការឆ្លើយតប កថាខណ្ឌ ១១។

11. វិធាន ៣៩(៦) នៃវិធានផ្ទៃក្នុងចែងថា ឯកសារដែលបានដាក់នៅចំពោះមុខ អ.វ.ត.ក. "ត្រូវដាក់ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះស្របតាមច្បាប់ជាធរមាន វិធានផ្ទៃក្នុងនេះ សេចក្ដីណែនាំអនុវត្ត និងសេចក្ដីសម្រេចរបស់ចៅក្រម តាមករណីសមស្រប" ។

12. មាត្រា ៣. ១៧ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ("សេចក្ដីណែនាំអនុវត្ត") ពន្យល់ថា៖

> ការកែតម្រូវឯកសារក្នុងសំណុំរឿង ត្រូវដាក់ឯកសារដោយប្រើទម្រង់ក្នុងលិបិក្រម ឆ។ ការកែប្រែឯកសារដើម ត្រូវមានការព្រមព្រៀងពីក្រឡាបញ្ជី ចំណែកឯការកែតម្រូវឯកសារបកប្រែ ត្រូវបានការយល់ព្រមពីអង្គភាពកបប្រែភាសា។ ប្រសិនបើមានការធ្វើបច្ចុប្បន្នភាពអត្ថបទឯកសារដែលបានដាក់ ត្រូវដាក់ឯកសារនេះដោយមានការបង្ហាញចំណុចដែលបានកែប្រែនៅទំព័រដែលបានកែប្រែ។

13. មាត្រា ៦ ដែលកំណត់លើបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ចែងថា៖

៦.១ ឯកសារត្រូវដាក់ជាមួយបញ្ជីមូលដ្ឋាន ដែលប្រើប្រាស់ជាឯកសារយោង នៅក្នុងឯកសារនោះ។ បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ទាំងនោះ និងសំរង់ពេញលេញនៃមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោងនីមួយៗ ដោយបញ្ជាក់អំពីបទប្បញ្ញត្តិ កថាខណ្ឌ ឬលេខទំព័រ ដែលត្រូវដកស្រង់ព្រមជាមួយនឹងការពន្យល់ ដែលតម្រូវលើកឡើងដោយកថាខណ្ឌនោះ។ ប្រសិនបើ មូលដ្ឋានសំអាងផ្លូវច្បាប់នោះមានកំរាស់លើសពី ១០ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង [...] ទំព័រជាភាសាខ្មែរ ត្រូវដាក់មកត្រឹមទំព័រទី១ នៃអត្ថបទនោះរួមជាមួយផ្នែកដែលទាក់ទង ដោយបញ្ជាក់នៅក្នុងបញ្ជីនៃឯកសារនោះថា មូលដ្ឋានសំអាងផ្លូវច្បាប់នេះលើសពី ១០ ជាភាសាអង់គ្លេស ឬ បារាំង [...]

៦.៣ ឯកសារត្រូវដាក់ជាមួយសេចក្តីចម្លងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលប្រើប្រាស់ជាឯកសារយោង លើកលែងតែឯកសារយោងមាននៅក្នុងកំរងអត្ថបទច្បាប់របស់ អ.វ.ត.ក. មានផ្សាយនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក. និងឯកសារដែលមានជាសាធារណៈ។

៦.៤ ប្រសិនបើបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលប្រើប្រាស់ជាឯកសារយោង បានដាក់ម្តងមកហើយ នៅក្នុងរឿងក្តី ឬចំណាត់ការដូចគ្នា បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោងនេះ មិនចាំបាច់ដាក់ចំលងម្តងទៀតឡើយ ប៉ុន្តែបុគ្គលដែលដាក់ឯកសារនៅពេលក្រោយត្រូវបង្ហាញអំពីបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោង និងលេខកំណត់ត្រារបស់តុលាការ និងលេខ ERN ដែលបានដាក់កាលពីលើកមុន [...]។

14. នៅក្នុងអនុស្សរណៈឆ្នាំ ២០១១ ដែលបានយោងទៅលើមាត្រា ៦.៣ នៃសេចក្តីណែនាំអនុវត្តខាងលើ អង្គជំនុំជម្រះបានជូនដំណឹងភាគីនៅក្នុងសំណុំរឿង ០០២ ថា៖

[...] អង្គជំនុំជម្រះសាលាដំបូងលើកលែងឱ្យភាគីដោយពុំចាំបាច់ដាក់ឯកសារចម្លងមូលដ្ឋានសំអាងផ្លូវច្បាប់ *ដូចជា* យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* និងលិខិតុបករណ៍អន្តរជាតិ ដែលមានអត្ថិភាពជាសាធារណៈ និងងាយស្រួលរកបានដោយអង្គជំនុំជម្រះ និងភាគីទាំងអស់។ មូលដ្ឋានសំអាងផ្លូវច្បាប់ ដែលពុំមានភាពងាយស្រួលស្វែងរក តម្រូវឱ្យដាក់នៅក្នុងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ស្របតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ រាល់មូលដ្ឋានសំអាងផ្លូវច្បាប់ទាំងអស់ត្រូវតែរាយបញ្ជីនៅក្នុងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់សម្រាប់ភាពងាយស្រួលស្វែងរក។

## ឃ. ការពិភាក្សា

***<u>កំណត់សម្គាល់បឋម</u>***

15. នៅក្នុងសារណាតប មេធាវីការពារក្តីបានជូនដំណឹងអង្គជំនុំជម្រះ និងភាគីឆ្លើយតបថា បច្ចុប្បន្ន ខ្លួនកំពុងធ្វើការកែតម្រូវសារណាបណ្តឹងសាទុក្ខ[21]។ ការកែតម្រូវរបស់មេធាវីការពារក្តីបានដាក់នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០[22]។ សំណើសុំរបស់សហមេធាវីនាំមុខដែលថា ការកែតម្រូវលើសារណាបណ្តឹងសាទុក្ខ ត្រូវតែដាក់ក្នុងពេលវេលាជាក់លាក់ និងមិនពាក់ព័ន្ធលើខ្លឹមសារនោះ[23]ចាត់ទុកជាអសារបង់។

***ការទាមទារសំណើទីមួយ***

16. សហមេធាវីនាំមុខបានស្នើសុំអង្គជំនុំជម្រះឱ្យណែនាំមេធាវីការពារក្តីដាក់ឡើងវិញនូវបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដោយភ្ជាប់ (i) មូលដ្ឋានសំអាងផ្លូវច្បាប់ទាំងអស់ដែលបានយោងនៅក្នុងសារណាបណ្តឹងសាទុក្ខ និងក្នុងចំណោមនោះ មេធាវីការពារក្តី (ii) "ត្រូវកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវ" នៃមូលដ្ឋានសំអាងផ្លូវច្បាប់ដែលមានស្រាប់នៅក្នុងសំណុំរឿង និង (iii) ភ្ជាប់ច្បាប់ចម្លងនៃមូលដ្ឋានសំអាងផ្លូវច្បាប់ទាំងអស់ដែលពុំទាន់មាននៅក្នុងសំណុំរឿង[24]។

17. ទាក់ទងទៅនឹងចំណុចទីពីរ មេធាវីការពារក្តីទទួលស្គាល់ថា តារាងមូលដ្ឋានសំអាងផ្លូវច្បាប់មានកំហុស និងអះអាងថា ខ្លួនបានរៀបចំរួចរាល់ហើយដើម្បីដាក់ស្នើសុំធ្វើការកែតម្រូវនៃតារាងនេះ ពេលណាការកែតម្រូវលើសារណាបណ្តឹងសាទុក្ខត្រូវបានដាក់ជាមុនសិន[25]។ បើទោះជាមេធាវីការពារក្តីចង្អុលបង្ហាញថា ធនធានរបស់ខ្លួនត្រូវបានកាត់បន្ថយយ៉ាងច្រើន ចាប់តាំងពីពេលដាក់សារណាបណ្តឹងសាទុក្ខ[26] យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តីទទួលបានអត្ថប្រយោជន៍នៃរយៈពេលលើសពីបីខែ ដើម្បីពិនិត្យឡើងវិញលើសារណាបណ្តឹងសាទុក្ខ និងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់របស់ខ្លួន។ ដោយពិចារណាឃើញថា ការកែតម្រូវនឹងត្រូវការការបកប្រែភាសាបន្ថែម និងថា ការបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខ បានដាក់នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២០ ដែលជារយៈពេលចាប់ផ្តើមគិតសម្រាប់សារណាតបនោះ អង្គជំនុំជម្រះបង្គាប់មេធាវីការពារក្តីឱ្យដាក់សំណៅកែតម្រូវនៃ

---

[21] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៦។

[22] សំណើសុំកែតម្រូវលើឯកសារលេខ **F54** ឯកសារលេខ **F54/Corr-1** ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០ និងជូនដំណឹងនៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២០។

[23] ការឆ្លើយតប កថាខណ្ឌ ១២(២)។

[24] សំណើសុំ កថាខណ្ឌ ៦ ដល់ ៧។

[25] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៦ ដល់ ៧។

[26] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៩។

តារាងមូលដ្ឋានសំអាងផ្លូវច្បាប់ ក្នុងរយៈពេល ២៨ ថ្ងៃគិតចាប់ពីពេលចេញសេចក្ដីសម្រេចនេះ។ តារាងកែតម្រូវនេះ ត្រូវវាយបញ្ចូលម្ដិតនៃមូលដ្ឋានសំអាងផ្លូវច្បាប់ដែលបានយោងនៅក្នុងសារណាបណ្ដឹងសាទុក្ខ និងកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់នូវមូលដ្ឋានសំអាងផ្លូវច្បាប់ណាដែលមានស្រាប់នៅក្នុងសំណុំរឿង ដូចមានចែងក្នុងមាត្រា ៦.១ និង ៦.៤ នៃសេចក្ដីណែនាំអនុវត្ត។

18. កត់សម្គាល់ថា អនុស្សរណៈឆ្នាំ ២០១១ ត្រូវបានចេញក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះពិចារណាឃើញថា ខ្លឹមសារនៃអនុស្សរណៈនេះនៅតែមានអត្ថិភាពសម្រាប់សំណុំរឿង ០០២/០២ អាស្រ័យហេតុនេះ តារាងមូលដ្ឋានសំអាងផ្លូវច្បាប់ដែលបានកែតម្រូវត្រូវមានច្បាប់ចម្លងនៃមូលដ្ឋានសំអាងផ្លូវច្បាប់ទាំងអស់ដែលបានយោងនៅក្នុងបណ្ដឹងសាទុក្ខ ហើយពុំទាន់មាននៅក្នុងសំណុំរឿង និងពុំមានភាពងាយស្រួលក្នុងការស្វែងរក។

19. ដោយពិចារណាលើសម្អាងហេតុខាងលើ អង្គជំនុំជម្រះទទួលយកការទាមទារសំណងទីមួយនេះ។

***<u>ការទាមទារសំណងទីពីរ</u>***

20. អង្គជំនុំជម្រះយល់ស្របជាមួយនឹងសហមេធាវីនាំមុខថា សហមេធាវីពុំគប្បីទទួលផលប៉ះពាល់ដោយសារសំណើកែតម្រូវពេញលេញនៃតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ (និងការកែតម្រូវលើសារណាបណ្ដឹងសាទុក្ខ) ដែលនឹងត្រូវដាក់ក្នុងរយៈពេលលើសពីបីខែបន្ទាប់ពីកាលបរិច្ឆេទដាក់សារណាលើកដំបូង[27]។ ដោយពិចារណាឃើញថា ការដាក់សំណើកែតម្រូវនេះ ជៀសពុំរួចនឹងត្រូវពន្យារពេលដល់ភាគីឆ្លើយតប ដូច្នេះ ទទួលយកសំណើសុំទីពីរ។

## ខ. ផ្នែកសម្រេចសេចក្ដី

21. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

**ប្រកាស**សំណើសុំរបស់សហមេធាវីនាំមុខពាក់ព័ន្ធទៅនឹងការកែតម្រូវសារណាបណ្ដឹងសាទុក្ខ

ជាអសារបង់

**ទទួលយក**សំណើសុំដទៃទៀតរបស់សហមេធាវីនាំមុខ

---

[27] ការឆ្លើយតប កថាខណ្ឌ ១០ ដល់ ១១។

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F56/2/2

**បង្គាប់**មេធាវីការពារក្ដីដាក់សំណៅកែតម្រូវនៃតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ក្នុងរយៈពេល ២៨ ថ្ងៃគិតចាប់ពីពេលចេញសេចក្ដីសម្រេចនេះ ដោយភ្ជាប់ជាមួយនូវឯកសារចម្លងនៃមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលបានយោងនៅក្នុងសារណាបណ្ដឹងសាទុក្ខ ដែលពុំទាន់មាននៅក្នុងសំណុំរឿង និងពុំងាយស្រួលក្នុងការស្វែងរក ស្របតាមមាត្រា ៣.១៧ ៦.១ ៦.៣ និង ៦.៤ នៃសេចក្ដីណែនាំអនុវត្តដែលត្រូវបានវិសោធនកម្មដោយអនុស្សរណៈឆ្នាំ ២០១១

**ផ្ដល់**ឱ្យសហមេធាវីនាំមុខចំនួន ២៨ ថ្ងៃសម្រាប់ដាក់តារាងមូលដ្ឋានសំអាងផ្លូវច្បាប់គិតចាប់ពីថ្ងៃដាក់សារណាតបមួយភាសា។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

*សេចក្ដីសម្រេចលើសំណើពាក់របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការមិន អនុវត្តន៍របស់ ខៀវ សំផន តាមមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ*